**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ: ៦១៣៣/២៣ មស.សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការកំណត់សមាសភាព និងតួនាទីភារកិច្ចរបស់
# ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន

## រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជា
## ប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២៣១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- អនុក្រឹត្យលេខ ៣២៥ អនក្រ.បក ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- យោងតាមការចាំបាច់

## សម្រេច

**ប្រការ១.-**

សេចក្តីសម្រេចនេះ មានគោលបំណងកំណត់អំពីសមាសភាព និងតួនាទីភារកិច្ចរបស់ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន ព្រមជាមួយនឹងយន្តការនៃការអនុវត្តការងារ។

**ប្រការ២.-**

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. ថ្នាក់ដឹកនាំជាអនុប្រធាន ឬ សមាជិកនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ | ប្រធាន |
| ២. អគ្គលេខាធិការ ឬ អគ្គនាយក ទទួលបន្ទុកកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. ប្រធាននាយកដ្ឋាន ទទួលបន្ទុកកិច្ចការបុគ្គលិក ឬ ធនធានមនុស្ស | សមាជិកអចិន្ត្រៃយ៍ |
| ៤. ប្រធាននាយកដ្ឋាន ទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុ | សមាជិក |
| ៥. ប្រធាននាយកដ្ឋាន ទទួលបន្ទុកកិច្ចការរដ្ឋបាល | សមាជិក។ |



ផ្លូវវេត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ: +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

សមាសភាពជាក់ស្តែងរបស់ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន ត្រូវទទួលស្គាល់ដោយសេចក្តីសម្រេចរបស់ក្រសួង ស្ថាប័នសាមី។ ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន អាចមានសមាសភាពផ្សេងទៀតតាមការសម្រេចរបស់ក្រសួង ស្ថាប័នសាមី។

**ប្រការ៣.-**

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន មានតួនាទី និងភារកិច្ចដូចតទៅ៖

- ដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈក្នុងក្របខណ្ឌក្រសួង ស្ថាប័ន
- ចូលរួមអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្នុងនោះផ្តោតទៅលើ៖ (១)ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី (២)ការលើកកម្ពស់ប្រសិទ្ធភាពការងារ និង (៣)ការរៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម
- អនុវត្តការត្រួតពិនិត្យឡើងវិញ និងវិភាគមុខងាររបស់ក្រសួង ស្ថាប័ន
- រៀបចំ និងអភិវឌ្ឍកម្មវិធីពង្រាយមន្ត្រីរាជការ
- រៀបចំ និងអភិវឌ្ឍកម្មវិធីដើម្បីអភិវឌ្ឍសមត្ថភាពមន្ត្រី និងស្ថាប័ន
- រៀបចំផែនការសកម្មភាពការងារកែទម្រង់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដោយបន្សុីទៅនឹងវិធានការគន្លឹះទាំងបីរបស់រាជរដ្ឋាភិបាល និងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ដោយសហការជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- ចូលរួមកិច្ចប្រជុំទៀងទាត់ប្រចាំត្រីមាសនិងផ្អែកតាមការចាំបាច់ តាមការអញ្ជើញរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីពិនិត្យវឌ្ឍនភាពការងារ បញ្ហាប្រឈម ដំណោះស្រាយ និងវិធានការនានា
- រៀបចំកិច្ចប្រជុំរបស់ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន ស្តីពីវឌ្ឍនភាពការងារជាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន។

**ប្រការ៤.-**

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន ត្រូវផ្តល់របាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តតួនាទី និងភារកិច្ចប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ (នៅសប្តាហ៍ទី៣នៃខែចុងក្រោយ) មកនាយកដ្ឋានត្រួតពិនិត្យ និងវាយតម្លៃនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីធ្វើការបូកសរុបរបាយការណ៍ជូនគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ មុនពេលដាក់ជូនប្រមុខរាជរដ្ឋាភិបាល។

**ប្រការ៥.-**

ប្រធាន អនុប្រធាន សមាជិក និងសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៨កើត ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជា**

**ប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ**

ហ៊ុន_ម៉ានី

**<u>កន្លែងទទួល៖</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី

  "ដើម្បីជូនជ្រាប"
- ដូចប្រការ៥
- ឯកសារ កាលប្បវត្តិ